ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
លេខ :...២.៤៤៧.អ.ជ.ប.ជ.អ.

ភ្នំពេញ, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៤

ជម្រាបជូន
លោកនិពន្ធនាយកនៃសារព័ត៌មាន ភ្នំពេញ ប៉ុស្ត៍

កម្មវត្ថុ៖ ការចុះផ្សាយអត្ថបទក្រោមចំណងជើងថា "មួយគ្រួសារផ្ទុកមេរោគអេដស៍១៥នាក់" នៃសារព័ត៌មាន ភ្នំពេញ ប៉ុស្ត៍ លើទំព័រមុខ លេខ១៣៤០ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៤ ។

ខ្ញុំបានអានអត្ថបទសារព័ត៌មានរបស់លោកក្រោមចំណងជើងថា "មួយគ្រួសារផ្ទុកមេរោគអេដស៍១៥នាក់" លើទំព័រមុខ លេខ១៣៤០ ចេញផ្សាយថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៤ ។ ខ្ញុំទទួលស្គាល់តួនាទីសារព័ត៌មានរបស់លោកក្នុងការផ្សព្វផ្សាយនូវអត្ថបទ ឬព័ត៌មានជូនដល់សាធារណជន ឬអ្នកអានរបស់លោក ។ ការផ្សព្វផ្សាយព័ត៌មាន មតិ ឬការវិភាគទាំងឡាយដែលបាននិងកំពុងតែធ្វើឡើងដោយសេរីនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានឆ្លុះបញ្ចាំងនូវការលើកកម្ពស់សេរីភាពសារព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្សពិតប្រាកដ ។ ជាមួយនោះខ្ញុំក៏សូមអំពាវនាវដល់អ្នកទទួលខុសត្រូវសារព័ត៌មានទាំងអស់ឱ្យចូលរួមរក្សាភាពសម្ងាត់របស់អ្នកផ្ទុកមេរោគអេដស៍ ។ ការរក្សាភាពសម្ងាត់នេះ ជាវិធីការពារកុំឱ្យមានការរើសអើងនៅក្នុងសង្គម ឯការរើសអើងក្រោមរូបភាពណាក៏ដោយ ជាការរំលោភសិទ្ធិមនុស្សមួយដ៏ធ្ងន់ធ្ងរ ។ ដើម្បីទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និង ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់អ្នកផ្ទុកមេរោគអេដស៍ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ដែលព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានទ្រង់ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ។ នៅក្នុងជំពូកទី៧ មាត្រា៣៣ នៃច្បាប់នេះ នៅវាក្យខណ្ឌទី១ចែងថា "អ្នកមានមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS) ត្រូវទទួលបានការរក្សាភាពសម្ងាត់" ។ ការចេញផ្សាយរូបថតច្បាស់ៗ ទីកន្លែងរស់នៅពិតប្រាកដ និងស្ថានភាពឯទៀតនៃអ្នកមានមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS) ដែលលោកបានធ្វើ ជាការទម្លាយភាពសម្ងាត់របស់អ្នកជំងឺអេដស៍ ដែលជាការរំលោភបំពានលើមាត្រា៣៣ នៃច្បាប់ស្តីពីការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ។ ការរំលោភបំពាននេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០០ (ប្រាំម៉ឺន) រៀល ដល់ ២០០០០ (ម្ភៃម៉ឺន) រៀល និង

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ៦ខែ ដូចមានចែងក្នុង ជំពូក១០ ស្តីពីទោសប្បញ្ញត្តិ ក្នុងមាត្រា៥១ នៃច្បាប់ខាងលើនេះស្រាប់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ មុននឹងចេញផ្សាយអត្ថបទថ្មីទៀត ខ្ញុំសូមឱ្យសារព័ត៌មានរបស់លោកធ្វើការប្រុងប្រយ័ត្ន ចេះរក្សាភាពសម្ងាត់ ចេះលាក់បាំងអត្តសញ្ញាណរបស់អ្នកផ្ទុកមេរោគអេដស៍ ដូចជាមិនបង្ហាញរូបថតច្បាស់ៗ ទីកន្លែងពិតប្រាកដ និង ស្ថានភាពឯទៀតដែលនាំឱ្យសាធារណជនស្គាល់មុខ ឬទីកន្លែងរស់នៅរបស់អ្នកផ្ទុកមេរោគអេដស៍ទាំងនោះ ។ ដោយយោងលើក្រមសីលធម៌ខ្ពស់របស់សារព័ត៌មានរបស់លោក ខ្ញុំសង្ឃឹមថាលោកនិពន្ធនាយកនឹងចាត់វិធានការគ្រប់យ៉ាង ដើម្បីកុំឱ្យមានការរំលោភបំពានលើសិទ្ធិរបស់អ្នកផ្ទុកមេរោគអេដស៍ ក៏ដូចជាការរំលោភបំពានលើច្បាប់ជាធរមានទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជាយើង ។

សូមលោកទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អៀង - ម៉ូលី

ចម្លងជូន :
-ក្រសួងព័ត៌មាន
-កាលប្បវត្តិ-ឯកសារ